# សាលារៀនសាធារណៈ LYNN
# សេវាកម្មសុខភាពសាលារៀន
# <u>គោលការណ៍ណែនាំក្នុងការមិនបញ្ជូនកូនមករៀន</u>

**គ្រុនក្តៅ**
សម្រាប់សីតុណ្ហភាព 100° ឬលើសពីនេះ សូមទុកកូនលោកអ្នកនៅផ្ទះរហូតទាល់តែជាសះស្បើយសម្រាប់រយៈពេល 24 ម៉ោងដោយមិនមានការប្រើប្រាស់ថ្នាំបន្ថយកម្តៅដូចជាថ្នាំ acetaminophen (Tylenol) ឬ ibuprofen (Motrin ឬ Advil)ជាដើម។

**ការក្អួត**
សូមទុកកូនលោកអ្នកនៅផ្ទះសម្រាប់រយៈពេល 24 ម៉ោង បន្ទាប់ពីភាគចុងក្រោយ និងរហូតទាល់តែកូនលោកអ្នកអាចទប់អាហារឬទឹកមិនឲ្យក្អួតចេញបាន។

**រាករូស**
សូមទុកកូនលោកអ្នកនៅផ្ទះរហូតទាល់តែលែងមានរោគសញ្ញាសម្រាប់រយៈពេល 24 ម៉ោង។

**កន្ទួល**
កន្ទួលរមាស់ ប្រសិនបើកន្ទួលមានលក្ខណៈខុសធម្មតាឬលាយជាមួយការក្តៅខ្លួន សូមឲ្យអ្នកផ្តល់សេវាសុខភាពពិនិត្យរោគវិនិច្ឆ័យ ហើយចេញលិខិតសម្រាប់ការវិលត្រលប់ចូលរៀនវិញ។

**ផ្តាសសាយ ក្អក ហៀរសំបោរ**
ប្រសិនកូនរបស់លោកអ្នកមិនគ្រុនក្តៅទេ ប៉ុន្តែក្អក ឬកណ្តាស់ម្តងម្កាល ហើយអាចគ្រប់គ្រងការបន្ទោរបង់បាន ពួកគេអាចចូលរៀនបាន។ សូមទុកកូនលោកអ្នកនៅផ្ទះ ប្រសិនបើពួកគេធ្លាក់ឈាម ឬក្អកច្រើន ឬបត់ជើងច្រើនដង។

**ជំងឺហឺត**
ប្រសិនបើកូនលោកអ្នកពិបាកដកដង្ហើម ក្អក ដកដង្ហើមខ្លីៗឬតឹងដើមទ្រូងដែលមិនធូរស្រាលបន្ទាប់ពីប្រើថ្នាំហើយ សូមទុកកូនរបស់អ្នកនៅផ្ទះ ហើយទាក់ទងអ្នកផ្តល់សេវាថែទាំសុខភាពរបស់ពួកគេ។

**ឈឺក**
ប្រសិនបើឈឺកហើយក្តៅខ្លួន ហើមកាឡាតែន មានការឈឺចាប់ឬពិបាកលេប សូមយកកូនទៅឲ្យអ្នកផ្តល់សេវាថែទាំសុខភាពពិនិត្រ។

**ឈឺក្រពះ**
សូមទុកកូននៅផ្ទះប្រសិនបើពួកគេឈឺលើសពី 2 ម៉ោងនិង/ឬគ្រុនក្តៅ ក្អួត ឬរាករូស។

**ឈឺក្បាល ឈឺត្រចៀក ឈឺធ្មេញ**
កូនលោកអ្នកអាចចូលរៀនបាន ប្រសិនបើការឈឺចាប់អាចគ្រប់គ្រងបានដោយឱសថបានវេជ្ជបញ្ជា ខណៈដែលរង់ចាំការណាត់ជួបទន្តបណ្ឌិតឬវេជ្ជបណ្ឌិត។ ប្រសិនបើឈឺចាប់ខ្លាំង មិនបាចឲ្យកូនមករៀនទេ។

**ភ្នែកក្រហម ឬហូរទឹកភ្នែក**
ប្រសិនបើផ្នែកឡើងក្រហម ឬ រមាស់ និងមានហូរទឹកភ្នែកពណ៌លឿង បៃតង ចូរយកកូនទៅឲ្យគ្រូពេទ្យពិនិត្យ។

